គណបក្ស សិទ្ធិមនុស្ស
HUMAN RIGHTS PARTY
លេខ ០៦៣១/១១ គ.ស.ម
បំរើ ការពារ កសាង

**គោរពជូន**

**ឯកឧត្តម ស ខេង**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

កម្មវត្ថុ ៖ សំណើដោះលែងសកម្មជនគណបក្សសិទ្ធិមនុស្សពីររូប ដែលប៉ូលីសខេត្តកំពង់ចាមបានចាប់ខ្លួនដោយគ្មានកំហុស

យោងតាមកម្មវត្ថុដូចបានជម្រាបជូនដូចខាងលើនេះ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា សកម្មជនគណបក្សសិទ្ធិមនុស្សពីររូបនៅឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាមគឺលោក **ផាន ផា** ជាអនុប្រធានគណៈកម្មាធិការប្រតិបត្តិគណបក្សសិទ្ធិមនុស្សឃុំទន្លេបិទ និងលោក **ភូមិ យាន** តំណាងភូមិទួលខ្សាច់ ឃុំទន្លេបិទ របស់គណបក្សសិទ្ធិមនុស្ស បានត្រូវប៉ូលីសនាំខ្លួនយកទៅឃុំនៅក្នុងស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម ប្រមាណម៉ោង៦ល្ងាច កាលថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១១ បន្ទាប់ពីពួកគាត់ចេញពីសង្កេតការណ៍ ពិនិត្យឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។ ករណីចាប់ខ្លួននេះគណបក្សសិទ្ធិមនុស្សបានទទួលព័ត៌មានមកថា កាលពីថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១១ មួយថ្ងៃមុនថ្ងៃចាប់ខ្លួននេះ សកម្មជនថ្នាក់ឃុំរបស់គណបក្សសិទ្ធិមនុស្ស លោក **ផាន ផា** គ្រាន់តែយកឯកសារទាក់ទងទៅនឹងកិច្ចការបោះឆ្នោត ឯកសារគោលនយោបាយ និងឯកសារប្រវត្តិសាស្ត្រខ្មែរ ទៅប្រគល់ឲ្យសកម្មជនភូមិរបស់គណបក្សសិទ្ធិមនុស្ស លោក **ភូមិ យាន** ផ្ទាល់តែប៉ុណ្ណោះ ។ ពេលប្រគល់នោះមេភូមិលោក **សៀរ អែ** ដែលជាអ្នកធ្លាប់ស្គាល់គ្នា ប្រទាំងគ្នាបានឃើញក៏បានឆក់យកឯកសាទាំងនោះទៅប្រគល់ឲ្យប៉ូលីស ។ មួយថ្ងៃបន្ទាប់មកក៏មានការនាំខ្លួនយកទៅ ឃុំនៅស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម ។

អាស្រ័យដូចបានជំរាបជូនខាងលើនេះ ខ្ញុំសូម **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** មេត្តាជួយអន្តរាគមន៍ឲ្យមានការដោះលែងសកម្មជនគណបក្សសិទ្ធិមនុស្សទាំងពីររូបខាងលើនេះឲ្យមានសេរីភាព ដើម្បីអាចមកបំរើការងារនយោបាយរបស់ពួកគាត់តាមគោលការណ៍ប្រជាធិបតេយ្យ សេរី ពហុបក្ស ។

សូមឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ទទួលនូវការគោរពរាប់អានអំពីខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែកញ្ញា ឆ្នាំ២០១១

**ប្រធានគណបក្សសិទ្ធិមនុស្ស**

HUMAN RIGHTS PARTY

**គឹម សុខា**

Address: #72-74, Street 598, Sangkat Boeung Kok 2, Khan Tuol Kok, Phnom Penh, Cambodia.
Tel: (+855) 17 303 900 - http://www.hrpcambodia.info - hrpcambodia@yahoo.com